-យោងតាមចំណារអនុម័តរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សំរេច

**ប្រការ១ :** ត្រូវបានបន្ថែមខ្លឹមសារដូចខាងក្រោមនៅក្នុងប្រការ១ នៃសេចក្តីសំរេចលេខ ៣៧ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន AZ Distribution CO.LTD ធ្វើជាដៃគូផ្គត់ផ្គង់ស្បៀងអាហារ សំភារៈ បរិក្ខារ ឧបករណ៍ គ្រប់ប្រភេទជូនក្រសួងការពារជាតិ ចាប់ពីឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០០៤ :

-សេចក្តីសំរេចនេះមិនអោយជាន់ជាមួយសេចក្តីសំរេចលេខ ៤០ សសរ ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការប្រគល់សិទ្ធិអោយក្រុមហ៊ុនសូគីមិច ផ្គត់ផ្គង់ជូនក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

-ចំពោះគ្រឿងចក្រវិស្វកម្មចំនួន ២៧៩ គ្រឿង សំរាប់ផែនការ ៥ឆ្នាំ ដែលស្នើដោយឯកឧត្តមរដ្ឋមន្ត្រី ទៀ បាញ់ ហើយដែលត្រូវទូទាត់តាមតំណាក់កាលៗរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៩ ទៅ ត្រូវរក្សាទុកជូន ក្រុមហ៊ុន AZ Distribution CO.LTD ដដែល ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធក្រុមហ៊ុន AZ Distribution CO.LTD មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

====

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ៥១ សសរ

## ស្តីពីការកែសំរួលកំណត់ទីតាំងលេងល្បែងស៊ីសង កាស៊ីណូ

* * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ផ្អែកតាមស្ថានភាពការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១ :** ត្រូវបានបំពេញបន្ថែមទៅលើលិខិតបទដ្ឋាន និងការអនុញ្ញាតរបស់រាជរដ្ឋាភិបាល ដែលមានជាធរមាន នូវការកំណត់រូបកំណត់ទីតាំងលេងល្បែងស៊ីសង កាស៊ីណូ ដូចតទៅ :

-រាជធានីភ្នំពេញ និងផ្ទៃដីជុំវិញរាជធានីភ្នំពេញ ក្នុងរង្វង់ ដែលមានវិជ្ជមាត្រ ២០០ គីឡូម៉ែត្រ ដោយយកចំណុចភ្នំដូនពេញ ជាចំណុចផ្ចិត ជាតំបន់គ្មានលេងល្បែងស៊ីសង កាស៊ីណូ និង ក្លឹបកំសាន្ត ឬ ក្លឹបផ្សងសំណាងដែលមានល្បែងស៊ីសង ។

-តំបន់សៀមរាបអង្គរ ជាតំបន់គ្មានលេងល្បែងស៊ីសង ។

**ប្រការ ២ :** ចំពោះទីតាំងលេងល្បែងស៊ីសង កាស៊ីណូ ណៃក្លឹប និងក្លឹបកំសាន្តប្រើម៉ាស៊ីនថែមពេលក្នុងយកលុយ នៅ ភ្នំពេញ ដែលមានការអនុញ្ញាត រាជរដ្ឋាភិបាលនឹងពិនិត្យផលប៉ះពាល់នៃសម្រួលតាមការព្រមព្រៀង រវាងរាជរដ្ឋាភិបាល ជាមួយក្រុមហ៊ុន ។ ទីតាំងលេងល្បែងស៊ីសង កាស៊ីណូ និងក្លឹបកំសាន្តទាំង ពីរនេះ ត្រូវបញ្ចប់សកម្មភាពត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ។ ចាប់តាំងពីថ្ងៃចេញសេចក្តី សំរេចនេះទៅរហូតដល់ពេលបញ្ចប់ស្ថាប័នមានសមត្ថកិច្ចត្រូវ :

-ពិភាក្សាកំណត់ទីតាំងលេងល្បែងស៊ីសង កាស៊ីណូ ត្រូវធ្វើជាថ្មី

-កំណត់ប្រាក់ពន្ធ និងបំណុលផ្សេងៗរវាងរដ្ឋ និង ក្រុមហ៊ុន

-ផ្ទេរទីតាំងលេងល្បែងស៊ីសងចាស់ អោយធ្វើអាជីវកម្ម សេវាកម្ម ក្រៅពីល្បែងស៊ីសង នឹងត្រូវចុះកិច្ច សន្យាថ្មី ។

-ក្រុមហ៊ុនត្រូវបញ្ចប់នូវការលេកសនាចុះកិច្ចសន្យានាំភ្ញៀវមកលេង ក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៩៩ នៅទីតាំងចាស់ ហើយបង្វែរទៅទីតាំងថ្មី ក្នុងករណីកសាងសង់ទាន់ពេល ។

**ប្រការ ៣ :** បណ្តាទីតាំងលេងល្បែងស៊ីសង កាស៊ីណូ ក្លឹបកំសាន្ត ឬ ក្លឹបផ្សងសំណាង មានល្បែងស៊ីសង ដែលមានច្បាប់អនុញ្ញាតរួចហើយ ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់តាមកិច្ចសន្យា អំពីប្រការហាមឃាត់មិនអោយ ពលរដ្ឋខ្មែរចូលលេង ។ ការល្មើសនឹងប្រការនេះ ត្រូវត្រួតពិនិត្យ និងមានវិធានការជាបន្ទាន់ លុប ចោលនូវកិច្ចសន្យា ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ ក្រសួង-ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ កាស៊ីណូ ណៃក្លឹប និង ក្លឹបកំសាន្ត ប្រើម៉ាស៊ីនថែមពេលក្នុងយកលុយ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★